## កីឡា និងលំហាត់ប្រាណ

យើងផ្តល់ជូនទូវកីឡា និងសកម្មភាពចម្រុះ ជាច្រើនប្រភេទក្នុងមួយឆ្នាំៗសំរាប់មនុស្សគ្រប់វ័យ និងគ្រប់សមត្ថភាព។ គំរូអំពីកម្មវិធីផ្សេងៗ ដែលយើងផ្តល់ជូន រួមមានដូចតទៅ ៖

### កីឡាសំរាប់យុវជន និងក្មេងជំទង់

- កីឡាបាល់បោះ
- កីឡាបាល់ហ្វុតបលហ្វ្លេ-ក
- កីឡារត់ប្រណាំង
- កីឡាបាល់ទះយុវតី
- កីឡាបាល់ទាត់

### ថ្នាក់កីឡាសំរាប់យុវជន

- កីឡាទិន្នីស
- កីឡាបាល់ទាត់ក្នុងអាគារ
- ថ្នាក់បង្រៀនកីឡា
- កីឡាបាល់ធី

### ថ្នាក់ និងក្រុមនីតិជន

- សម្ពន្ធកីឡាបាល់ឃិក្ខ
- កីឡាបាល់ហ្វុតបលហ្វ្លេ-ក លំហាត់ប្រា ណលម្ហែ, NIA, យ៉ូហ្គា, យ៉ូហ្គា លេត
- កីឡាតិន្នីស
- លំហាត់ប្រាណដោយប្រើវិធីភ្លីអូមេទ្រិក្ស
- កីឡាបាល់ទាត់
- កីឡាបាល់បោះ

**បើកីឡាដែលលោកអ្នកចូលចិត្តមិនឃើញមាន ចុះនៅក្នុងនេះទេ, សូមលោកអ្នកប្រាប់យើងខ្ញុំ។ យើងខ្ញុំទទួលស្វាគមន៍មតិយោបល់ក្នុង ការ-បង្កើតកម្មវិធីថ្មីៗបន្ថែមទៀតជានិច្ច។**

# កម្មវិធីលម្ហែ

មជ្ឈមណ្ឌលសហគមន៍ហៃភ្វញត៍ (High Point Community Center) ផ្តល់ទូវថ្នាក់បង្រៀន, សកម្មភាពកម្សាន្ត, ព្រមទាំងព្រឹត្តិការណ៍ពិសេសៗជាច្រើនទៀតជូនប្រជាសហគមន៍ទាំងមូល ដោយមិនគិតអំពីអាយុ, សមត្ថភាព, ឬស្ថានភាពសេដ្ឋកិច្ចឡើយ។

### សកម្មភាពគ្រួសារ

យើងផ្តល់ព្រឹត្តិការណ៍ផ្សេងៗជាច្រើនជូនគ្រួសារប្រជាសហគមន៍ទាំងអស់ជាប្រក្រតី។ កាលពីអតីត,យើងបានផ្តល់នូវព្រឹត្តិការណ៍ដូចជាការសម្តែងល្បែងឆ្កិនភ្នែក,បុរសសត្វពស់ពត់ពេន (Roving Reptile Man), និងវិទ្យាសាស្ត្រឆេវឆាវ (Mad Science).

### ព្រឹត្តិការណ៍ពិសេស

រព្ឋព្រឹត្តិការណ៍និងពិធីបុណ្យជាច្រើនប្រភេទក្នុងមួយឆ្នាំៗដូចជា ៖

- ការប្រមាញ់ស៊ុត
- រាត្រីកម្សាន្តក្រៅផ្ទះកម្រិតថ្នាក់ជាតិ
- បុណ្យធ្លាក់ចម្លែក
- សាយមាសនៃបុណ្យថ្ងៃអំណរគុណព្រះ
- ការល្បៀងភោជនាហារថ្ងៃបុណ្យសហគមន៍

### ទារកថត្តលរ័

សូមអញ្ជើញចូលមកពិនិត្យមើលកម្មវិធីយកទារកថត្តលរ័ (ទើបរៀនដើរ)មកដាក់ឲ្យលេងកម្សាន្តរបស់យើងឲ្យបានជាប្រក្រតី ដោយរាប់សរុបទាំងកម្មវិធី Indoor Playground (ទីធ្លាកម្សាន្តក្នុងអគារ)។ យើងក៏មានផ្តល់ជូនទូវថ្នាក់បង្រៀន,ព្រឹត្តិការណ៍ពិសេស,និង កម្មវិធីបោះជុំរុំជាច្រើនប្រភេទផ្សេងទៀតផងដែរ។

### យុវជន

យើងផ្តល់ថ្នាក់បង្រៀនមុខវិជ្ជានិងកម្មវិធីច្រើនប្រភេទក្នុងត្រីមាសនីមួយៗ ដោយសរុបមានដូចជាតន្ត្រី, កីឡា, ខ្ទឹមសារថ្ងៃបុណ្យ, សិល្បៈ/, និងកម្មវិធីច្រើនថែមទៀត។

### ក្មេងជំទង់

មជ្ឈមណ្ឌលក្មេងជំទង់ (Teen Center) គឺជាកន្លែងកម្សាន្តមួយសម្រាប់លេងបុកប៊ីយ៉ា, មើលទូរទស្សន៍, ឲ្យគេជួយធ្វើហូមវើក, រៀន ធ្វើម្ហូប, ធ្វើដំណើរទស្សនាកម្សាន្តទៅកាន់ទីកន្លែងផ្សេងៗ, ព្រមទាំងទទួលបាននូវកាលានុវត្តភាពសិក្សារៀនសូត្រដទៃជាច្រើនទៀត។

### នីតិជន

យើងមិនមែនត្រឹមតែជាកន្លែងសំរាប់ក្មេងកំសាន្តប៉ុណ្ណោះទេ។ សូមអញ្ជើញចូលរួមជាមួយនីតិជន (មនុស្សពេញវ័យ) ឯទៀតៗ ដើម្បី កំសាន្តកម្មវិធីដែលគួរឲ្យរំភើប និងប្រកបដោយចំណេះដឹងផ្សេងៗ។ លោកអ្នកអាចចុះឈ្មោះសំរាប់រៀនតែមួយថ្ងៃ, រៀននៅចុងសប្តាហ៍, ឬរៀនប្រចាំសប្តាហ៍ដោយខ្លួនឯងផ្ទាល់។ យើងផ្តល់សកម្មភាពជាច្រើនប្រភេទ, ចាប់ពីថ្នាក់រៀនប្យ៉ាណូទៅដល់ថ្នាក់រៀនយ៉ូហ្គា។ ផ្ទៃមេឃជាដែនកម្រិត!

### នីតិជនចាប់ពីអាយុ 50 ឆ្នាំឡើងទៅ

យើងសហការជាមួយបុគ្គលិកកម្មវិធីលម្ហែ Life Long Recreation ដើម្បីផ្តល់យានជំនិះសំរាប់ដំណើលម្ហែ, កម្មវិធីលំហាត់ប្រាណ, កម្មវិធីក្លឹប, និងសកម្មភាពនានាជាច្រើនទៀត។

### ប្រជាជនពិសេស

កម្មវិធីឯកទេសកម្ម (Specialized Programs) ផ្តល់កម្មវិធីនិងព្រឹត្តិការណ៍ពិសេសៗនៅរៀងរាល់ត្រីមាសក្នុងតំបន់ក្រុងស៊ីអាថ្ថល ភាគខាងលិច (West Seattle)។ បើលោកអ្នកមានសំណួរអ្វីមួយស្តីអំពីការចូលរួមនេះ, សូមទូរស័ព្ទទាក់ទង 206-684-4950 ។

**យើងត្រូវការគ្រូបង្ហាត់ចំណេះដឹងផ្សេងៗ ៖** តើលោកអ្នកមានទេពកោសល្យពិសេស ឬមួយក៏មានចំណាប់អារម្មណ៍ក្នុងការចែករំលែក ទេពកោសល្យឬចំណេះដឹងណាមួយជាមួយអ្នកអ្នកដទៃឬទេ? យើងខ្ញុំតែងស្វែងរកការជួយផ្តល់មតិយោបល់សំរាប់ថ្នាក់ថ្មីៗជានិច្ច។ សូមទូរស័ព្ទទាក់ទងលេខ 206-684-7422 ។

## កម្មវិធីមើលក្មេងក្នុងវ័យសិក្សា

កម្មវិធីមុននិងក្រោយពេលម៉ោងសិក្សានៅសាលា (Before and After School Programs) ផ្តល់ការមើលក្មេងដោយ មិត្តភាព (child-friendly care) ដើម្បីជួយសម្រួលភាពងាយស្រួលជូនឪពុក/ម្តាយរបស់បណ្តាសិស្សពីថ្នាក់មត្តេយ្យដល់ថ្នាក់ទី 5 ដែលធ្វើការ។ យើងមានកម្មវិធីដែលឆ្លើយតបទៅនឹងតម្រូវការមើលក្មេងក្នុងវ័យសិក្សា ដោយរួមមានទូវការបោះជុំរុំរដូវក្តៅផង។

ជម្រើសនៃកម្មវិធីមើលក្មេងដែលមានតម្លៃថោកសមរម្យក្នុងតំបន់ West Seattle, តំបន់ High Point CC ត្រូវបានផ្តល់អាជ្ញា ប័ណ្ណពេញសិទ្ធិដោយក្រសួង DSHS, ដែលនេះមានន័យថាកូនរបស់លោកអ្នកអាចទទួលបានការចំណាយពេលប្រដបដោយគុណភាពខ្ពស់នៅខាងក្រៅសាលារៀននិងគេហដ្ឋាន។ បុគ្គលិកការងាររបស់យើងធ្វើការយ៉ាងស្វិតស្វាញ ដើម្បីផ្តល់កាលានុវត្តភាព និងការជួយលើកចិត្តឲ្យក្មេងម្នាក់ៗចេះធ្វើការជ្រើសរើសនិងណែនាំទិសដៅខ្លួនឯងក្នុងការបញ្ចេញទឹក ដៃឆ្នៃប្រតិដ្ឋនិងទេពកោសល្យតែ មួយគ្មានពីររបស់ពួកគេ។

ថ្លៃឈ្នួលកម្មវិធីគឺមានតម្លៃស្មើៗគ្នាពីខែមួយទៅខែមួយនៅក្នុងរយៈពេល 10 ខែ (178 ថ្ងៃ)ក្នុងឆ្នាំកិស្សា។ ត្រូវបង់ថ្លៃឈ្នួលបន្ថែម សំរាប់អស់ទាំងថ្ងៃក្រៅថ្ងៃសិក្សា និងថ្ងៃក្នុងសប្តាហ៍ឈប់សម្រាក។ បុគ្គលិកកម្មវិធីផ្តល់អាហារស្រាលសំរាប់ពេលព្រឹកនិងថ្ងៃរសៀល។

អាហារូបករណ៍ (Scholarships) អាចមានបម្រុងជូនរហូតដល់ទៅ 90% សំរាប់បណ្តាគ្រួ សារដែលមានគុណសម្បត្តិសំរាប់ ជំនួយនេះ ហើយយើងទទួលយកមូលនិធិជំនួយមើលក្មេងរបស់ក្រសួង DSHS ។

**ទស្សនវិស័យនៃឧទ្យាន និងកម្មវិធីលម្ហែនៃក្រុងស៊ីអាថ្តល ៖**
យើងបង្កើតសគមន៍តាមរយៈ/មនុស្ស, ឧទ្យាន, និងកម្មវិធីនានា។

**ឧទ្យាន និងកម្មវិធីលម្ហែនៃក្រុងស៊ីអាថ្តល ហើយនិងក្រុមប្រឹក្សា ARC រួមសហការជាមួយគ្នាដើម្បីបម្រើលោកអ្នក!**
កម្លាំង និងដៃគូដ៏សំខាន់បំផុតរបស់ឧទ្យាន និងកម្មវិធីលម្ហែនៃក្រុង ស៊ីអាថ្តល (Seattle Parks and Recreation) គឺក្រុមប្រឹក្សា នៃសមាគមកម្មវិធីលម្ហែ (Associated Recreation Council – ARC)។ ក្រុមប្រឹក្សា ARC គឺជាអង្គការឥតរកកម្រៃឯករាជ មួយ ដែលឧទ្ទិសកិច្ចឧបត្ថម្ភរបស់ផងខ្លួនចំពោះការបង្កើតកម្មវិធីលម្ហែក្នុង ទីក្រុងស៊ីអាថ្តល ដោយជួយផ្តល់នូវកម្មវិធី និងសេវាកម្មនានាដល់ សហគមន៍របស់យើង ព្រមទាំងផ្តល់កិច្ចប្រឹក្សាយោបល់ដល់ស្នង ការ ឧទ្យានក្នុងការបង្កើតកម្មវិធី, សេវា, មន្ទីរ, និងប្រតិបត្តិការ ផ្សេងៗ។

**ព័ត៌មានស្តីអំពីក្រុមប្រឹក្សាយោបល់**
ក្រុមប្រឹក្សាយោបល់ (Advisory Council) នីមួយៗមានសមាស ភាពផ្តុំឡើងពីបណ្តាពលរដ្ឋស្ម័គ្រចិត្ត ទៅតាមការចាត់តាំងរបស់ស្នងការឧទ្យាន និងកម្មវិធីលម្ហែ (Parks and Recreation Superintendent), ហើយក្រុមនេះធ្វើការជាមួយបុគ្គលិកឧទ្យាន, ដើម្បីជួយផ្តល់អនុសាសន៍ក្នុងការបង្កើតកម្មវិធី និងសកម្មភាពទៅ តាមប្រភេទផ្សេងៗ ដែលគេនឹងផ្តល់ជូនដល់មជ្ឈមណ្ឌលសហគមន៍ ឬមជ្ឈដ្ឋានប្រជាពលរដ្ឋណាមួយទៅតាមតម្រូវការ។

ក្រុមប្រឹក្សា ARC ផ្តល់ការទទួលខុសត្រូវ,ការឧបត្ថម្ភដល់ក្រុមប្រឹក្សាយោបល់, អង្គភាពដឹកនាំ, អង្គភាពអប់រំ, និងអង្គភាពដឹកនាំទិសដៅនៃការបង្កើតបទបញ្ជាផ្ទៃក្នុងដែលផ្តោតលើមូលដ្ឋានសហគមន៍នានាទៅតាមតម្រូវការក្នុងឆ្នាំសារពើពន្ធនីមួយៗ។

លោកអ្នកក៏អាចធ្វើឲ្យមានការផ្លាស់ប្តូរសំខាន់ៗទាំងនេះបានដែរដោយចូលរួមជាមួយក្រុមប្រឹក្សាយោបល់របស់សហគមន៍ហៃភុញ (High Point's Advisory Council) នៅក្នុងកិច្ចប្រជុំប្រចាំខែណា មួយរបស់ពួកគេ។

**បេសកកម្មរបស់ក្រុមប្រឹក្សាសហគមន៍ហៃភុញគឺ ៖**

- ដើម្បីតភ្ជាប់ទំនាក់ទំនងទៅនឹងសហគមន៍ដោយការផ្តល់សេវាប ម្រើអតិថិជនប្រដបដោយគុណភាពខ្ពស់,បង្កើនគុណភាពជីវភាពរស់នៅ,និងជួយបុគ្គលម្នាក់ៗក្នុងការស្វែងយល់អំពីសក្តានុភាពលេញលេញរបស់ពួកគេ។
- ដើម្បីកាត់បន្ថយឧបសគ្គ, បង្កើនការធានាសមភាព, លើកស្ទួយការរាប់អានគ្នា, និងផ្តល់លទ្ធភាពប្រើប្រាស់សេវាកម្មផ្សេងៗ ដោយតម្លៃថោកសមរម្យ។
- ដើម្បីផ្តល់កាលានុវត្តភាពប្រកបដោយក្តីសង្ឃឹម និងទំនួលខុសត្រូវផងនានា ដែលអាចជួយលើកកម្ពស់ដល់ជីវិតរស់នៅដោយសុខុមាលភាពយូរអង្វែង និងការកែកម្សាន្តដោយសេចក្តីស្រស់ស្រាយ, ការរៀនសូត្រដោយគំនិតឆ្នៃប្រតិដ្ឋ, និងការរុករកផងពលរដ្ឋ។

# កម្មវិធីកម្សាន្តនៅសហគមន៍ហៃភុញ!

- កម្មវិធីទារកថត្តលរ័, យុវជន, ក្មេងទំទង់, នីតិជន, និងមនុស្សចាស់
- កម្មវិធីមើលក្មេងនៅមុន និងក្រោយពេលចេញពីសាលារៀន
- កម្មវិធីបោះជុំរុំរដូវក្តៅ
- កម្មវិធីអត្តពលកម្មក្នុងអគារសំរាប់ទារកថត្តលរ័
- ថ្នាក់បប្រៀនក្មេងមុនវ័យចូលសាលា
- ថ្នាក់បង្រៀនរាំ/របាំ
- សម្ពន្ធកីឡា
- កម្មវិធីគ្រួសារ
- ព្រឹត្តិការណ៍ពិសេស
- កម្មវិធីចូលលេងបាល់បោះ និងបាល់ទះភ្លាមៗដោយមិនពិបាកសមហាត់
- កម្មវិធីកីឡាពីងប៉ុង

**សូមមើលខាងក្នុងសំរាប់ស្វែងយល់ព័ត៌មានស្តីអំពីសកម្មភាពផ្សេងៗជាច្រើនទៀត!**

**ជំនួយហិរញ្ញវត្ថុដែលមានបម្រើការ**

ឧទ្យាននិងកម្មវិធីលម្ហែនៃទីក្រុងស៊ីអាថ្តល និងក្រុមប្រឹក្សា ARC ផ្តល់អាហារូបត្ថម្ភផ្សេងៗ ដើម្បីជួយកម្មវិធីកាត់បន្ថយការចេញថ្លៃ ដោយខ្លួនឯងនានា។

អាហារូបត្ថម្ភអាចមានបម្រុងជូនរហូតដល់ទៅ 90% សំរាប់កម្មវិធីមើលក្មេង។ អាហារូបត្ថម្ភក៏អាចមានបម្រុងជូនរហូតដល់ទៅ 80% ផងដែរសំរាប់កម្មវិធីលម្ហែទាំងអស់ផ្សេងទៀត។ តម្រូវឲ្យមានការដាក់ពាក្យសុំ។

យើងខ្ញុំទទួលយកជំនួយឧបត្ថម្ភជាប្រាក់ពី DSHS ហើយយើងខ្ញុំគឺជាមន្ទីរមើលក្មេងដែលមានអាជ្ញាប័ណ្ណ DSHS ។

**ធនធានផ្សេងៗទៀត**
បើលោកអ្នកចង់បានសេវាកម្មដែលពុំមានផ្តល់ជូនក្នុងកន្លែងរបស់យើងខ្ញុំ, នោះសូមកុំខ្លាចក្រែងនឹងសួរយើងខ្ញុំអំពីធនធាននានា ដែល អានមានបម្រើការនៅក្នុងសង្កាត់ភូមិដ្ឋាននេះ។ យើងខ្ញុំប្រហែលជាអាចភ្ជាប់លោកអ្នកទៅនឹងទីភ្នាក់ងារដែលជាដៃគូរបស់យើងណា មួយនៅក្នុងសង្កាត់ភូមិដ្ឋាននេះ។

# របស់របរសំរាប់ជួល

មជ្ឈមណ្ឌល High Point Community Center ជួលបន្ទប់ និងគ្រឿងតុបតែងលម្អប្រដបដោយគុណភាពខ្ពស់សំរាប់ គ្រប់សេចក្តីត្រូវការសន្និបាត និងព្រឹត្តិការណ៍ទាំងអស់របស់លោកអ្នក។

**មានទីធ្លាបន្ទប់ស្រស់ល្អប្រណីតដូចជា ៖**

**បន្ទប់សំរាប់បម្រើការទូទៅ**
- ចំណុះ 184 នាក់

**បន្ទប់គ្រឹះស្ថានកីឡា**
- ចំណុះ 376 នាក់

**បន្ទប់ប្រជុំ**
- មានបម្រុងជូនពីចំណុះ 10 នាក់ទៅដល់ 184 នាក់

**ចង្ក្រានបាយខ្នាតពាណិជ្ជកម្មឥតខ្ចោះ**

**មានជួលឧបករណ៍ និងគ្រឿងតុបតែងបន្ថែមផ្សេងៗដូចជា ៖**

**កៅអី និងតុ**
- មានបម្រុងជូនភ្ញៀវរហូតដល់ទៅ ២០០ នាក់

**ផ្ទាំងសំពត់សសំរាប់បញ្ចាំងភាពយន្ត**

**វេទិការួមជាមួយឧគ្ឃោសនសព្ទ**

**ឧបករណ៍ឲ្យពិន្ទុ និងលៃកំណត់ពេល**
- សំរាប់ប្រើប្រាស់ក្នុងគ្រឹះស្ថានកីឡា

**ល្បែងសំរាប់ទារកថត្តលរ័លេងកម្សាន្តនៅពេលមានពីធីជប់លៀងផ្សេងៗ**
- មានបម្រុងជូនតែត្រូវចេញតម្លៃបន្ថែម

អាស្រ័យដោយហេតុមានការផ្លាស់ប្តូរប្រចាំឆ្នាំ និងថ្លៃជួលបុគ្គលិកធ្វើការ, យើងខ្ញុំមិនមានតម្លៃកំណត់សំរាប់ការជួលទាំឡាយ បោះផ្សាយនៅក្នុងនេះទេ។ សូមសួរយើងខ្ញុំអំពីតម្លៃនៃការជួលបន្ទប់ និងឧបករណ៍សំរាប់ព្រឹត្តិការណ៍លោកអ្នកដោយផ្ទាល់។

យើងខ្ញុំរង់ចាំជួយធ្វើឲ្យព្រឹត្តិការណ៍ពិសេសលើកក្រោយរបស់រលោកអ្នករឹតតែមានសោភ័ណភាពល្អត្រកាលឡើង។

សូមអញ្ជើញទាក់ទងយើងខ្ញុំថ្ងៃនេះ!

# មជ្ឈមណ្ឌលសហគមន៍ហៃភុញត៍



6920 34TH AVE SW
SEATTLE, WA 98126
(206) 684-7422
(206) 684-7402 (FAX)

SEATTLE PARKS AND RECREATION

ARC

**ការបង្កើតសហគមន៍តាមរយះ**
**មនុស្ស, ឧទ្យាន, និងកម្មវិធីនានា។**